00184957

A104/II/7

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៥)

| | | |
|---|---|---|
| នៅចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន | ប្រធាន |
| | ចៅក្រម Rowan DOWNING | |
| | ចៅក្រម ន័យ ថុល | |
| | ចៅក្រម Katinka LAHUIS | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ៣០ មេសា ២០០៨ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2008
ម៉ោង (Time/Heure): 15 h 10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

---

សាធារណៈ:

## សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទនឹងប្រពន្ធរបស់គាត់

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 30 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY

**សហមេធាវីការពារក្ដី**
អាង ឧត្ដម
Michael G. KARNAVAS

## I. សេចក្តីផ្តើម

១. អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ដែលបានប្តឹងកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ដោយសហមេធាវីរបស់ជនត្រូវចោទប្រឆាំងនឹងលិខិតរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៨ "លិខិតរបស់សហចៅក្រមស៊ើបអង្កេត"។

២. ក្នុងលិខិតនោះ សហចៅក្រមស៊ើបអង្កេតបាននិយាយថា៖
ក្នុងការឆ្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ទាក់ទងទៅនឹងសំណើសុំការអនុញ្ញាតឱ្យ អៀង សារី ចូលសួរសុខទុក្ខ អៀង ធីរិទ្ធ យើង សូមជំរាបថា ដោយសារតែការស៊ើបអង្កេតសំណុំរឿងលេខ 002/19-09-2007-ECCC-OCIJ នៅកំពុងតែបន្ត យើង មិនមានផែនការផ្លាស់ប្តូរលក្ខខណ្ឌនៃការចូលសួរសុខទុក្ខដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះទេ។ ដូច្នេះហើយ ជំនួបរវាង អៀង ធីរិទ្ធ និងកូនក្តីរបស់លោក មិនអាចធ្វើទៅបានទេនាពេលបច្ចុប្បន្ននេះ។

៣. អង្គបុរេជំនុំជម្រះ សម្រេចទទួលយកបណ្តឹងឧទ្ធរណ៍នេះកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨។ អង្គបុរេជំនុំជម្រះប្រកាសអំពីការទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយពិចារណាថា:
ជាបញ្ហាមួយពាក់ព័ន្ធទៅនឹងសិទ្ធិដែលត្រូវគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង ដោយពិចារណាទៅភារកិច្ចដូចមានចែងក្នុង វិធាន២១(១) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះយល់ឃើញថាបណ្តឹងឧទ្ធរណ៍នេះសមស្របទៅនឹងខ្លឹមសារដូចមានចែងក្នុង វិធាន៧៤(៣)-ច នៃវិធានផ្ទៃក្នុង។

៤. ក្នុងចន្លោះពេលនោះ សហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨ បានធ្វើអនុស្សរណៈមួយច្បាប់ជូនប្រធានមន្ទីរឃុំឃាំងនៃអ.វ.ត.ក ដែលអនុញ្ញាតឲ្យលោក អៀង សារី និង លោកស្រីអៀង ធិរិទ្ធ ជួបគ្នាបានម្តងក្នុងមួយសប្តាហ៍ ។ យោងតាមសហចៅក្រមស៊ើបអង្កេត ការអនុញ្ញាតនេះ គួរតែអាចផ្តល់ជូនបានចាប់តាំងពីពេលដែលកិច្ចស៊ើបសួរសំខាន់ៗមួយចំនួនពីមុនមកត្រូវបានបញ្ចប់។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៥. កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ សហមេធាវី បានប្តឹងឧទ្ធរណ៍ ដោយយោងទៅលើ អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨ ដូចដែលបាន រៀបរាប់ខាងលើ ។ ដូចនេះ អង្គបុរេជំនុំជម្រះយល់ថាបញ្ហានៃបណ្តឹងឧទ្ធរណ៍ គឺពាក់ព័ន្ធទៅ នឹងសេចក្តីសម្រេចចុងក្រោយនេះ ។ ចំណុចនេះ នឹងចៀសវាងបញ្ហាស្មុគស្មាញពាក់ព័ន្ធទៅនឹង ស្ថានភាពនៃសេចក្តីសម្រេចចុងក្រោយនេះ ក្រោយពេលអង្គបុរេជំនុំជម្រះសម្រេចលើបណ្តឹងឧ ទ្ធរណ៍នេះ។

៦. កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ និងបានប្រកាសថា សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងបណ្តឹងឧទ្ធរណ៍ទេ ទោះបីជាពួកគេ មិនយល់ស្របជាមួយអំណះអំណាងខាងអង្គហេតុ និងអង្គច្បាប់ដែលបានលើកឡើងដោយ សហមេធាវីក៏ដោយ។

៧. ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាតបទេ។

៨. អង្គបុរេជំនុំជម្រះយល់ឃើញថាបញ្ហាត្រូវបានផ្តល់សំអាងយ៉ាងគ្រប់គ្រាន់ពីភាគី និងថាដូច្នេះ មិនចាំបាច់មានសវនាការផ្ទាល់មាត់ទេ ។ អង្គបុរេជំនុះជម្រះនឹងសម្រេចលើបណ្តឹងឧទ្ធរណ៍ នេះដោយផ្អែកលើសេចក្តីសន្និដ្ឋានលាយលក្ខអក្សរ ដោយយោងតាមវិធាន៧៧ នៃវិធានផ្ទៃក្នុង និងស្របជាមួយនឹងសេចក្តីណែនាំអនុវត្តអ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី១ ស្តីពី ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ។

## II. ការពិចារណា

៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បញ្ហានេះអាចទាញយកយោបល់ពីសំណើសុំរបស់ជនត្រូវ ចោទ និងលិខិតរបស់សហចៅក្រមស៊ើបអង្កេតដែលថា ជនជាប់ឃុំក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក មិនត្រូវបានអនុញ្ញាតឲ្យជួបគ្នា និងដែលជាការពិត ត្រូវតែបំបែកចេញដោយឡែកពី គ្នា។ ចំណុចនេះទំនងជា ផ្អែកទៅលើមូលដ្ឋាននៃការណែនាំរបស់សហចៅក្រមស៊ើបអង្កេត ។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

១០. អង្គបុរេជំនុំជម្រះក៏កត់សម្គាល់ផងដែរថា មន្ទីរឃុំឃាំងរបស់អ.វ.ត.ក គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា[១] និងច្បាប់កម្ពុជា។ ក្នុងសមត្ថកិច្ចរបស់ប្រធានមន្ទីរឃុំឃាំង របស់អ.វ.ត.ក ដូចមានចែងក្នុងមាត្រា ៣(២)នៃប្រកាសលេខ ២១៧ និងមាត្រា ៤(១) នៃនីតិវិធី ពន្ធនាគារ លេខ៣១ ប្រធានមន្ទីរឃុំឃាំង កំពុងតែដំណើរការអនុម័តវិធានស្តីពីការគ្រប់គ្រងជនជាប់ឃុំរង់ចាំការជំនុះជម្រះ ឬប្តឹងឧទ្ធរណ៍ចំពោះមុខ អ.វ.ត.ក ឬ ជនជាប់ឃុំក្រោមយុត្តាធិការរបស់ អ.វ.ត.ក (សេចក្តីព្រាងនៃវិធាននៃការឃុំឃាំងរបស់ អ.វ.ត.ក) ។

១១. អង្គបុរេជំនុំជម្រះពិចារណាថាសេចក្តីសម្រេចពីរប្រភេទ អាចមានប្រសិទ្ធិភាពលើការបំបែកចេញដោយឡែកពីគ្នា: (១) ដីកាឲ្យបំបែកចេញពីគ្នា ចេញដោយប្រធានមន្ទីរឃុំឃាំងស្របតាមសមត្ថកិច្ចដែលមានចែងក្នុងវិធានស្តីពីការឃុំឃាំងដែលបានដាក់ឲ្យអនុវត្ត និង (២) ដីកាស្តីពីការកម្រិតការទំនាក់ទំនងរវាងជនជាប់ឃុំ និងជនជាប់ឃុំដទៃទៀត ដែលចេញដោយសហចៅក្រមស៊ើបអង្កេត។

១២. ដោយផ្អែកលើការអានសំណុំរឿង និងសារណាដែលធ្វើឡើងដោយភាគី គ្មានការចង្អុលបង្ហាញថាប្រធានមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ជាអ្នកដែលមានយុត្តាធិការតែមួយគត់ក្នុងការបង្គាប់ឲ្យមានការបំបែកចេញពីគ្នា ដោយផ្អែកលើមូលដ្ឋានច្បាប់កម្ពុជា[២] ហើយសេចក្តីព្រាងវិធានស្តីពីការឃុំឃាំងនៅ អ.វ.ត.ក[៣] បានធ្វើការសម្រេចសេចក្តីនេះ។

---

[១] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ មាត្រា២៤ កិច្ចព្រមព្រៀងបន្ថែមរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាស្តីពីសុវត្ថិភាពនិងសន្តិសុខ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ មាត្រា៩ និងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា៣៣។

[២] នីតិវិធីពន្ធនាគារ លេខ០៣--ការបំបែកអ្នកទោសចេញពីគ្នា--ត្រូវបានអនុម័តដោយស្របទៅនឹងមាត្រា៤(៣) សេចក្តីប្រកាសស្តីពីរដ្ឋបាលពន្ធនាគារ។

[៣] វិធាន៣ នៃសេចក្តីព្រាងវិធានមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
C.E.T.C
4

00184961

A104/II/4

១៣. ទាក់ទងនឹងអំណាចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការកម្រិតនៃការជួបសួរសុខទុក្ខរវាងជនជាប់ឃុំ ដើម្បីការពារផលប្រយោជន៍កិច្ចស៊ើបសួរ វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង នៅក្នុងចំនុចដែលពាក់ព័ន្ធ ចែងថា:

> ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត (...) ។ ដើម្បីបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចៈ
> ខ-ចាត់វិធានការសមស្របដើម្បីផ្តល់សុវត្ថិភាព និងគាំទ្រដល់សាក្សីសំខាន់ៗ និងប្រភពដទៃទៀត។
> ឃ-តាមការចាំបាច់ ចេញដីកានានាដើម្បីបំពេញកិច្ចស៊ើបសួរ ដូចជាដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន និង ដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួន។

១៤. អង្គបុរេជំនុំជម្រះយល់ឃើញថា វិសាលភាពនៃវិធាន៥៥(៥) មានលក្ខណៈទូលាយគ្រប់គ្រាន់ក្នុងការផ្តល់យុត្តាធិការលើការកម្រិតនៃការជួបសួរសុខទុក្ខ រវាងជនត្រូវចោទដល់សហចៅក្រមស៊ើបអង្កេត និងបុគ្គលដទៃដែលមានផលប្រយោជន៍នៅក្នុងកិច្ចស៊ើបសួរ។

១៥. ប៉ុន្តែ វិធាន២១(២) នៃវិធានផ្ទៃក្នុង បានកម្រិតលើយុត្តាធិការមួយនេះ ដែលវិធាននេះចែងថា:

> វិធានការចាប់បង្ខំទាំងឡាយណាចំពោះបុគ្គលណាម្នាក់ត្រូវធ្វើឡើងដោយ ឬ ស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ។ វិធានការនេះត្រូវតែកម្រិត តឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី ដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និងដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឲ្យបានពេញលេញ។

១៦. ការសន្និដ្ឋានដូច្នេះ គឺស្របទៅនឹងការអនុវត្តនៅតាមបណ្តាតុលាការអន្តរជាតិនានា ដែលបានបង្កើតភាពខុសគ្នាយ៉ាងច្បាស់មួយរវាង (១) ការបំបែកជនជាប់ឃុំពីជនជាប់ឃុំទាំងអស់ ឬជនជាប់ឃុំមួយចំនួន ក្នុងគោលបំណងដើម្បីថែរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ នៅក្នុងពន្ធនាគារ និង សន្តិសុខ របស់ជនជាប់ឃុំ និង (២) ការកម្រិតការជួបសួរសុខទុក្ខរវាងជនជាប់ឃុំ និង បុគ្គលដទៃផ្សេងទៀត ដើម្បីចៀសវាងការប៉ះពាល់ដល់លទ្ធផលនៃកិច្ចដំណើរការ



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

00184962

A104/II/7

នីតិវិធី។[៤] វិធានទាំងឡាយ ដែលនៅជាធរមាននៅតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) តុលាការឧក្រិដ្ឋម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ICTY) និង តុលាការឧក្រិដ្ឋកម្ម អន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ICTR) ចែងថា ស្ថាប័នតុលាការ មានយុត្តាធិការនៅក្នុង ករណីទីពីរ[៥] មិនមែនករណីទីមួយទេ។[៦]

១៧. ការអនុវត្តតាមតុលាការនានាបានបង្ហាញយ៉ាងច្បាស់ថា ស្ថាប័នតុលាការត្រូវតែចេញសេចក្តី សម្រេចមួយដែលមានសម្អាងហេតុលើការកម្រិតនៃការជួបសួរសុខទុក្ខ។[៧] តាមការទាញ សម្អាងបែបនេះ វាបង្ហាញឱ្យយើងឃើញយ៉ាងច្បាស់ថា ផលប្រយោជន៍មួយណា ដែលត្រូវ ការពារ ហើយការកម្រិតគួរផ្អែកលើការការពារផលប្រយោជន៍នោះ។

១៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែល ធ្វើឡើងនៅក្នុងដីកាចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ និង នៅក្នុងអនុស្សារណៈចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០០៨ មិនបានផ្តល់សម្អាងហេតុគ្រប់គ្រាន់ ។ សហចៅក្រមស៊ើបអង្កេត មិនបាន ពន្យល់អំពីថាតើកម្រិតទំនាក់ទំនងនេះ ជាវិធានការចាំបាច់ និងមានសមាមាត្រទៅនឹងការ

---

[៤] *រដ្ឋអាជ្ញា ទល់នឹង Germain Katanga and Mathieur Ngudjolo Chui* ICC-01/04-01/07 "សេចក្តីសម្រេច បដិសេធការហាមឃាត់ទំនាក់ទំនងនិងការជួបសួរសុខទុក្ខរវាង Germain Katanga និង Mathieu Ngudjolo" ចៅក្រម Syliva Steiner ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៨ (សេចក្តីសម្រេច Chui) ទំព័រ៨។

[៥] នៅ ICTY និង ICTR សេចក្តីសម្រេចម្រិតការជួបសួរសុខទុក្ខ ត្រូវចេញដោយ Registra តាមសំណើរបស់រដ្ឋអាជ្ញា ហើយត្រូវពិនិត្យដោយ ប្រធានតុលាការ។ នៅ ICC សេចក្តីសម្រេចបែបនេះ ត្រូវចេញដោយអង្គជំនុំជម្រះដែលទទួលបាន រឿងក្តីនេះ តាមសំណើរបស់រដ្ឋអាជ្ញា។ សូមអានវិធាន៦៤ នៃវិធានមន្ទីរឃុំឃាំងនៃ ICTY និង ICTR និង វិធាន ១០១ នៃ បទបញ្ជាតុលាការ ICC។

[៦] វិធាន៤៣ នៃវិធានឃុំឃាំងរបស់ ICTY វិធាន៣៨ នៃវិធានឃុំឃាំងរបស់ ICTR និង មាត្រា ២០១ នៃបទបញ្ញា Registra នៃ ICC។ សូមអានផងដែរនូវ សេចក្តីសម្រេច Chui ទំព័រ ៨ និង ៩។

[៧] វិធាន៦៤នៃ ICTY និង ICTR វិធានមន្ទីរឃុំឃាំង ICTR និង បទបញ្ញា ១០១ នៃបទបញ្ញាតុលាការ ICC។ សូមអាន: *រដ្ឋអាជ្ញា ទល់នឹង Delalic* IT-96-21-A "សេចក្តីសម្រេចរបស់ប្រធានតុលាការលើ បណ្តឹងរដ្ឋអាជ្ញាអំពីការបង្កើតកំណត់ សម្គាល់ រវាង Zejnil Delalic និង Zdravko Mucic" ប្រធានតុលាការអន្តរជាតិ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ទំព័រ ១៤។



PRE-TRIAL CHAMBER · ECCC · CETC · CHAMBRE PRÉLIMINAIRE

ការពារផលប្រយោជន៍នៃកិច្ចស៊ើបសួរ។ បន្ថែមលើចំនុចនេះ នៅក្នុងលិខិតនោះសហចៅក្រមស៊ើបអង្កេតមិនមានការយកចិត្តទុកដាក់លើចំនុចសំខាន់នៃសេចក្តីសម្រេច ដែលបណ្តាលឱ្យមានការបំបែកគ្នាជាក់ស្តែងមួយឡើយ។[៨]

១៩. ជនត្រូវចោទ អៀង សារី និង អៀង ធីរិទ្ធិ បានរៀបការជាប្តីប្រពន្ធអស់រយៈពេល៥៧ឆ្នាំ។ បទល្មើសដែលបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងកាលពី៣០ឆ្នាំមុន ដូច្នេះ ជនត្រូវចោទមានពេលពិភាក្សាអំពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ ក្នុងរយៈពេលនេះ។

២០. នៅក្នុងកាលៈទេសៈបែបនេះ វាមានលក្ខណៈមិនច្បាស់លាស់សម្រាប់អង្គបុរេជំនុំជម្រះអំពីបញ្ហាដែលថា ការកម្រិតទំនាក់ទំនងរវាងជនត្រូវចោទទាំងពីរនេះ ផ្តល់ការការពារដល់ផលប្រយោជន៍នៃកិច្ចស៊ើបសួរយ៉ាងដូម្តេច។

២១. ម្យ៉ាងវិញទៀត អំឡុងពេលនៃវិធានការដ៏យូរបែបនេះ ដែលបានកំណត់តាំងពីកិច្ចស៊ើបសួរចាប់ផ្តើមនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ដោយមិនមានការផ្តល់យុត្តិកម្មសមស្របបានប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការប្រព្រឹត្តមកលើខ្លួនដោយមនុស្សធម៌។ ហេតុដូច្នេះ វិធានការនេះ ត្រូវបញ្ឈប់ជាដាច់ខាត។ ជនត្រូវចោទគួរទទួលបានការអនុញ្ញាតឱ្យជួបសួរសុខទុក្ខ អនុលោមតាមវិធាននៃការឃុំខ្លួនដែលអនុវត្តនៅមន្ទីរឃុំឃាំង អ.វ.ត.ក ។ អនុស្សារណៈរបស់សហចៅក្រមស៊ើបអង្កេត ដែលអនុញ្ញាតការជួបសួរសុខទុក្ខគ្នាម្តងក្នុងមួយសប្តាហ៍ មិនសមស្របទៅតាមវិធានទាំងនេះឡើយ ។

---

[៨] នៅក្នុងសេចក្តីសម្រេច Chui តុលាការព្រហ្មទណ្ឌអន្តរជាតិបានរកឃើញថា ដីកាបង្គាប់ដែលកម្រិតការសួរសុខទុក្ខមិនមានអនុភាពដាក់ឱ្យនៅបំបែកគ្នាបានឡើយ: សេចក្តីសម្រេច Chui ទំព័រ៨ និង ៩។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE 7

00184964

A104/II/7

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន:**

១. ទទួលយកបណ្ដឹងឧទ្ធរណ៍នេះ។

២. ដកចេញនូវសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលមាននៅក្នុងលិខិតចុះថ្ងៃទី២២ ខែមករា និង នៅក្នុងអនុស្សារណៈចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨។

៣. សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវមានអនុភាពដោយអនុញ្ញាតឱ្យជនត្រូវចោទ ជួបគ្នា អនុលោមតាមវិធានមន្ទីរឃុំឃាំងដែលដាក់ឲ្យអនុវត្ត នៅមន្ទីឃុំឃាំង អ.វ.ត.ក។

អនុលោមតាម វិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**ចេញដោយ** អង្គបុរេជំនុំជម្រះ ៧

ភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **នំយ ចុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គីមសាន**